# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ប្រចាំខែ មីនា ឆ្នាំ ២០១៥/March, 2015**

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញ/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ /Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trades | ៩ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ១១ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ១៣ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១៣ |
| ១.៧. វិស័យសំណង់/Construction | ១៤ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodities price** | **១៥** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price average: Brent; Dubai; WTI) | ១៥ |
| ២.២. ថ្លៃអង្ករ (Rice price: 5 ភាគរយ; 25 ភាគរយ; 100 ភាគរយ broken) | ១៥ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: SGP/MYS; TSR20) | ១៥ |
| **៣. ឧបសម្ព័ន្ធ** | **១៧** |


រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

**ប្រធាននាយកដ្ឋានស្ថិតិ**

**ខ្លឹមសារសង្ខេប/Executive summary**

១. នៅខែ មីនា ឆ្នាំ ២០១៥ សន្ទស្សន៍ថ្លៃ ទំនិញប្រើប្រាស់នៅភ្នំពេញបានកើនឡើង ០,១ ភាគរយ ធៀបនឹងខែកន្លងទៅ ឬ បានកើនឡើង ១,១ ភាគរយ ធៀបទៅនឹង១២ខែមុន ។ ការកើនឡើងនេះ គឺដោយសារ សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត បានកើនឡើង ០,៣ ភាគរយ ក្នុងនោះ សម្ភារៈសម្រាប់ថែរក្សានិងជួសជុលជំរកស្នាក់នៅបានកើនឡើង ១,១ ភាគរយ ។ សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ០,១ ភាគរយ ក្នុងនោះ ថ្លៃសេវាកម្មដឹកជញ្ជូនបានកើនឡើង ១,៤ ភាគរយ ។ តាមការធ្វើចំណោលគិតដល់ខែធ្នូ ឆ្នាំ ២០១៥ អតិផរណាប្រចាំឆ្នាំ (year on year) អាចមានអត្រា ៣,៥ ភាគរយ ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ១,៧ ភាគរយ ។

២. រូបិយវត្ថុទូទៅ (M2) មានកំណើនជាមធ្យម ១,៨៤ ភាគរយ/ខែ ឬ ២២ ភាគរយ/ឆ្នាំ បើគិតពីខែមេសា ឆ្នាំ ២០១៤ ដល់ខែ មីនា ឆ្នាំ ២១០៥ ។ ប្រាក់រៀលនៅលើទីផ្សារសរុបមានកំណើនជាមធ្យម ១,៨២ ភាគរយ/ខែ ឬ ២១,៨ ភាគរយ/ឆ្នាំ រូបិយប័ណ្ណបរទេស (ប្រាក់ដុល្លារ) មានកំណើនជាមធ្យម ១,៨៥ ភាគរយ/ខែ ឬ ២២,២ ភាគរយ/ឆ្នាំ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ (M2) គឺជាការឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចក្នុងស្រុក និងកំណើននៃតម្រូវការប្រាក់រៀលនិងប្រាក់ដុល្លារ ។ ប្រាក់រៀលនិងប្រាក់បរទេសមានកំណើនប្រហាក់ប្រហែលគ្នា ប៉ុន្តែដោយសារតែទំហំនៃប្រាក់បរទេស មានចំនួនច្រើនបានធ្វើឱ្យចំណែកនៃការចូលរួមរបស់ប្រាក់រៀលនៅក្នុងទីផ្សារនៅមានចំនួនតិចតួចនៅឡើយ ។

៣. ការនាំចូលសរុប៣ខែដើមឆ្នាំ មានជាទឹកប្រាក់ប្រមាណ ២.៧១២,៦ លានដុល្លារ ដែលកើនឡើង ២១,៣ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលក្នុងនោះការនាំចូលផលិតផលវាយនភ័ណ្ឌកើនឡើង ១៣,៨ ភាគរយ គ្រឿងយន្ត ២៣,១ ភាគរយ ប្រេងឥន្ធនៈ ១២,១ ភាគរយ បរិក្ខាសំណង់ ០,២ ភាគរយ និងការនាំចូលផលិតផលផ្សេងៗបានកើនឡើង ២៩ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន ។

ការនាំចេញសរុបមានជាទឹកប្រាក់ប្រមាណជា ២.១៧០ លានដុល្លារ ឬ បានកើនឡើង ៩,៨ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលការនាំចេញផលិតផលអង្ករបានកើនឡើង ៥៤,៥ ភាគរយ កៅស៊ូ ៣១,៥ ភាគរយ ផលិតផលកាត់ដេរកើនឡើង ៥,៨ ភាគរយ និងផលិតផលផ្សេងៗកើនឡើង ១៥,៩ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។

៤. រយៈពេល៣ខែដើមឆ្នាំ ២០១៥ ចំណូលក្នុងស្រុកអនុវត្តបានចំនួន ២.៦៣៣,៥៤ ពាន់លានរៀល គឺទាបជាង ១,៣៨ ភាគរយ នៃគោលដៅរយៈពេលបីខែ ប៉ុន្តែបានកើនឡើង ១៨,៦០ ភាគរយ បើធៀបទៅនឹងរយៈ ពេលដូចគ្នានៅឆ្នាំ ២០១៤ ។ ចំណូលចរន្តអនុវត្តបាន ២.៦២៣,៧៤ ពាន់លានរៀល គឺ ទាបជាង ១,១៨ ភាគរយ នៃគោលដៅរយៈពេលបីខែ ប៉ុន្តែ បានកើនឡើង ១៨,២៣ ភាគរយ គឺដោយសារការកើនឡើងនៃចំណូលសារពើពន្ធ ១៨,៣២ភាគរយ និង ចំណូលមិនមែនសារពើពន្ធ ១៧,២១ ភាគរយ ធៀបរយៈពេលដូចគ្នាក្នុង ឆ្នាំ

២០១៤ ។ ទន្ទឹមនឹងនេះ ចំណូលមូលធនអនុវត្តបាន ៩,៨០ ពាន់លានរៀល គឺ ខ្ពស់ជាង ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ។

ចំណាយសរុបអនុវត្តបានចំនួន ១.៩៥៨,០៨ ពាន់លានរៀល គឺទាបជាង ១១,២២ ភាគរយនៃគោលដៅរយៈពេល៣ខែ ឬ បានថយចុះ ២៥,២៣ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ដោយសារការពង្រឹងការអនុវត្តថវិកាតាមកម្មវិធី អង្គភាពថវិកាត្រូវបានដាក់ឲ្យអនុវត្តដំបូង ដែលធ្វើឲ្យមានភាពរអាក់រអួលខ្លះៗក្នុងការអនុវត្តថវិការបស់អង្គភាពទាំងនោះ ។ តុល្យភាពថវិកាចរន្តអតិរេកសាច់ប្រាក់ចំនួន ៦៨៣,៦៣ ពាន់លានរៀល ។ ជារួម នៅរយៈពេល៣ខែដើមឆ្នាំ ២០១៥ តុល្យភាពថវិកាចរន្តអតិរេកសាច់ប្រាក់ចំនួន ៨៩៤,០៤ ពាន់លានរៀល ។

## ១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends

### ១.១ ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និង សេវាកម្ម/Consumer price index

តាមប្រភពពីវិទ្យាស្ថានជាតិស្ថិតិបង្ហាញថា៖ នៅខែ មីនា ឆ្នាំ ២០១៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបានកើនឡើង ០,១ ភាគរយ ធៀបនឹងខែកន្លងទៅ ។ តាមការសង្កេត សន្ទស្សន៍ថ្លៃទំនិញនៅក្នុងខែ មីនា ឆ្នាំ ២០១៥ ដែលបានកើនឡើងនេះ មានសភាពចំរុះ គឺមកពីវិសមភាពនៃការផ្គត់ផ្គង់ និងពីឥទ្ធិពលនៃការកែសម្រួលអត្រាអាករពិសេស ការរឹតបន្តឹងវិធានការរដ្ឋបាលលើការប្រមូលពន្ធ និងការបង្កើនប្រាក់បៀវត្សរ៍ ជាដើម ។ សន្ទស្សន៍ថ្លៃទំនិញមួយចំនួន ដែលបានកើនឡើងដូចជា៖ សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត បានកើនឡើង ០,៣ ភាគរយ ក្នុងនោះ សម្ភារៈសម្រាប់ថែរក្សានិងជួសជុលជំរកស្នាក់នៅបានកើនឡើង ១,១ ភាគរយ ។ សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ០,១ ភាគរយ ក្នុងនោះ ថ្លៃសេវាកម្មដឹកជញ្ជូនបានកើនឡើង ១,៤ ភាគរយ ។ សន្ទស្សន៍ថ្លៃការកំសាន្តនិងវប្បធម៌បានកើនឡើង ០,៥ ភាគរយ ដោយសារកំណើនតម្រូវការក្នុងវិស័យទេសចរណ៍ ដូចជាភ្ញៀវអន្តរជាតិបានកើនឡើង មកពីស្ថានភាពអំរិភាពក្នុងតំបន់មានភាពប្រសើរជាងឆ្នាំកន្លងទៅ បើទោះបីជាមានបញ្ហាលើវិស័យអាកាសចរណ៍សកលខ្លះក្តី ។ រីឯអ្នកទេសចរក្នុងស្រុកវិញក៏មានការកើនឡើងខ្ពស់ ដោយមកពីស្ថានភាពនយោបាយក្នុងប្រទេសមានភាពចាស់ទុំប្រកបដោយវិជ្ជាជីវៈ និងប្រជាជនភាគច្រើនមានជីវភាពធូរធារ ។ សន្ទស្សន៍ថ្លៃភោជនីយដ្ឋានកើនឡើង ០,៣ ភាគរយ គឺមកពីកំណើនតម្រូវការប្រើប្រាស់ ការបង្កើនសមត្ថភាពវិជ្ជាជីវៈក្នុងការផ្តល់សេវា និងវិសមភាពរវាងតម្រូវការនិងការផ្គត់ផ្គង់ ។

ចំពោះសន្ទស្សន៍ថ្លៃមានការធ្លាក់ចុះដូចជា៖ សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះ បានថយចុះ ០,៥ ភាគរយ ក្នុងនោះ ថ្លៃគ្រឿងប្រើប្រាស់ធ្វើពីកែវសម្រាប់ប្រើលើតុនិងផ្ទះបាយបានថយចុះ ១,៤ ភាគរយ ថ្លៃសម្ភារៈនិងបរិក្ខាលំនៅដ្ឋាន បានថយចុះ ១,១ ភាគរយ ។ សន្ទស្សន៍ថ្លៃសុខាភិបាល គឺបាន

ថយចុះ ០,៦ ភាគរយ ក្នុងនោះ ថ្លៃសេវាសុខាភិបាលក្រៅមន្ទីរពេទ្យ បានថយចុះ ០,៥ ភាគរយ និង សន្ទស្សន៍ថ្លៃគមនាគមន៍ក៏បានថយចុះដែរ ដូចជាថ្លៃគ្រឿងទូរស័ព្ទនិងទូរសារបានថយចុះ ០,១ ភាគរយ ក្នុងខណៈដែលសន្ទស្សន៍ថ្លៃទំនិញមួយចំនួនទៀតស្ថិតនៅនឹង (សូមមើលតារាង ១.១) ។

| **តារាង ១.១ ÷ ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង ១២ក្រុម** | **ខែមុន** | **១២ខែមុន** |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **+០,១** | **+១,១** |
| ១-អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | ០,០ | +៤,១ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ០,០ | +៣,១ |
| ៣-សំលៀកបំពាក់និងស្បែកជើង | ០,០ | +២,៧ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | +០,៣ | -១,៩ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -០,៥ | +១,៣ |
| ៦-សុខាភិបាល | -០,១ | +០,៣ |
| ៧-ការដឹកជញ្ជូន | +០,១ | -១០,៥ |
| ៨-គមនាគមន៍ | -០,១ | -២,៦ |
| ៩-ការកំសាន្ត និងវប្បធម៌ | +០,៥ | +២,៥ |
| ១០-ការសិក្សា | ០,០ | -០,៥ |
| ១១-ភោជនីយដ្ឋាន | +០,៣ | +៣,៣ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +០,៣ | -៣,៨ |

បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបានកើនឡើង ១,១ ភាគរយ ។ ជាការសង្កេត ថ្លៃម្ហូបអាហារនៅតែបន្តកើនឡើង ប៉ុន្តែ ក្នុងកម្រិតទាបជាងឆ្នាំកន្លងទៅបន្តិច ដូចជា ថ្លៃសាច់ជ្រូកបានកើនឡើង ៥,៦ ភាគរយ ថ្លៃត្រីស្រស់បានកើនឡើង ៦,៣ ភាគរយ ថ្លៃសាច់ទាបានកើនឡើង ៥,០ ភាគរយ ។ ការប្រើប្រាស់សាច់ជ្រូកមានមេគុណចំនួន ៤,៩៣ ភាគរយ នៅលំដាប់ទី២ បន្ទាប់ពីត្រីដែលមានមេគុណចំនួន ៦,៧៥ ភាគរយ ក្នុងក្រុមម្ហូបអាហារនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុបដែលមានចំនួន ៤៦,២៧ ភាគរយ ។ ប្រការនេះបញ្ជាក់ថា សាច់ជ្រូក និងត្រីមានការប្រើប្រាស់យ៉ាងទូលំទូលាយក្នុងជីវភាពរស់នៅ (សូមមើលតារាង ១.១.ក) ។

| តារាង ១.១.ក ÷ ការប្រែប្រួលថ្លៃម្ហូបអាហារជាមូលដ្ឋានរយៈពេល ១២ ខែ (YOY) | | | | | |
|---|---|---|---|---|---|
| **មុខទំនិញ** | **២០១៤** | | **២០១៥** | | |
| | **មករា** | **កុម្ភៈ** | **មករា** | **កុម្ភៈ** | **មីនា** |
| អង្ករ | ២,៨% | ២,៩% | ០,៨% | ១,២% | ១,១% |
| សាច់គោ | ៩,១% | ៧,៧% | ៣,៤% | ៤,៤% | ២,៩% |
| សាច់មាន់ | ៧,១% | ៦,១% | ២,០% | ៣,២% | ២,៣% |
| សាច់ទា | ៦,៧% | ៧,៣% | ៣,៥% | ៥,៤% | ៥,០% |
| **សាច់ជ្រូក** | **៥,៥%** | **៥,៤%** | **៧,៤%** | **៧,៨%** | **៥,៦%** |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | ៦,៤% | ៥,៩% | ៤,៨% | ៦,៦% | ៥,៨% |
| **ក្នុងនោះត្រីស្រស់** | **៦,៥%** | **៦,០%** | **៥,៦%** | **៧,២%** | **៦,៣%** |
| ផ្លែឈើ | ៨,៥% | ៩,៣% | ៤,១% | ៧,១% | ៤,៣% |
| ផ្លែឈើស្រស់ | ៩,២% | ១០,២% | ៥,២% | ៨,៥% | ៥,៤% |
| បន្លែ | ៤,៥% | ២,៧% | ៥,៣% | ៧,៩% | ៨,៨% |
| បន្លែជាស្លឹក | ២,៦% | -០,៥% | ៥,២% | ១០,៨% | ១២,០% |
| បន្លែជាផ្លែ | ៦,៣% | ៣,២% | ៨,៥% | ១០,៥% | ១០,៨% |
| **កំណត់សម្គាល់៖** ប្រភពទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ | | | | | |

តាមការធ្វើចំណោលគិតដល់ខែ ធ្នូ ឆ្នាំ ២០១៥ អតិផរណាប្រចាំឆ្នាំ (year on year) អាចមានអត្រា ៣,៥ ភាគរយ ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ១,៧ ភាគរយ ។ អតិផរណាប្រចាំឆ្នាំជាមួយនឹងប្រទេសជិតខាងមួយចំនួនទៀត (សូមមើលតារាង ១.១.ខ ។

| **តារាង ១.១.ខ ÷ អតិផរណាប្រចាំឆ្នាំ** (%) | | | | | | | |
|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៤ | | | ២០១៥ | | | |
| | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា |
| ប្រទេសកម្ពុជា | 2.90 | 2.40 | 1.10 | 0.40 | 1.60 | 1.10 | 1.3e |
| ប្រទេសវៀតណាម | 3.23 | 2.60 | 1.84 | 0.94 | 0.34 | 0.93 | - |
| ប្រទេសថៃ | 1.48 | 1.26 | 0.60 | (0.41) | (0.52) | (0.57) | - |
| ប្រទេសម៉ាឡេស៊ី | 2.80 | 3.00 | 2.70 | 1.00 | 0.10 | 0.90 | - |
| ប្រទេសឥណ្ឌូនេស៊ី | 4.83 | 6.23 | 8.36 | 6.96 | 6.29 | 6.38 | - |
| ប្រទេសភីលីពីន | 4.30 | 3.70 | 2.70 | 2.40 | 2.50 | 2.40 | - |
| ប្រទេសចិន | 1.60 | 1.40 | 1.50 | 0.80 | 1.40 | 1.40 | - |
| ប្រទេសកូរ៉េខាងត្បូង | 1.20 | 1.00 | 0.80 | 0.80 | 0.50 | 0.40 | - |
| ប្រទេសជប៉ុន | 2.90 | 2.40 | 2.40 | 2.40 | 2.20 | 2.30 | - |
| **កំណត់សម្គាល់៖** ប្រភពទិន្នន័យ(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ (២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com | | | | | | | |

## ១.២ វិស័យហិរញ្ញវត្ថុ/Finance

### ១.២.១ រូបិយវត្ថុ

ចាប់តាំងពីខែ មេសា ឆ្នាំ ២០១៤ ដល់ខែ មីនា ឆ្នាំ ២១០៥ រូបិយវត្ថុទូទៅ (M2) មានកំណើនជាមធ្យមចំនួន ១,៨៤ ភាគរយ ក្នុងមួយខែ ឬ ប្រមាណ ២២ ភាគរយ ក្នុងមួយឆ្នាំ ។ សម្រាប់ប្រាក់រៀលនៅលើទីផ្សារសរុបមានកំណើនជាមធ្យមចំនួន ១,៨២ ភាគរយ ក្នុងមួយខែ ឬ ប្រមាណ ២១,៨ ភាគរយ ក្នុងមួយឆ្នាំ រីឯរូបិយប័ណ្ណបរទេស (ប្រាក់ដុល្លារ) មានកំណើនជាមធ្យមចំនួន ១,៨៥ ភាគរយ ក្នុងមួយខែ ឬ ប្រមាណជា ២២,២ ភាគរយក្នុងមួយឆ្នាំ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ (M2) គឺជាការឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចក្នុងស្រុក និងកំណើននៃតម្រូវការប្រាក់រៀល និងប្រាក់ដុល្លារ ។ ប្រាក់រៀល និងប្រាក់បរទេសមានកំណើនប្រហាក់ប្រហែលគ្នា ប៉ុន្តែដោយសារតែទំហំនៃប្រាក់បរទេស មានចំនួនច្រើនបានធ្វើឱ្យចំណែកនៃការចូលរួមរបស់ប្រាក់រៀលនៅក្នុងទីផ្សារនៅមានចំនួនតិចតួចនៅឡើយ ។

| តារាង ១.២.១ ÷ ស្ថានភាពរូបិយវត្ថុ២០១៣-២០១៥ (គិតជាពាន់លានរៀល) | | | | បំរែបំរួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | |
|---|---|---|---|---|---|---|
| សូចនាករ | ២០១៣ មីនា | ២០១៤ មីនា | ២០១៥ មីនា | ២០១៣ មីនា | ២០១៤ មីនា | ២០១៥ មីនា |
| រូបិយវត្ថុទូទៅ (M2) | 30,481 | 35,162 | 43,684 | 22.6 | 15.4 | 24.2 |
| រូបិយវត្ថុ (M1) | 4,501 | 5,376 | 6,628 | 13.0 | 19.5 | 23.3 |
| រូបិយវត្ថុក្រៅធនាគារ (៛) | 4,223 | 4,841 | 5,884 | 10.8 | 14.6 | 21.6 |
| ប្រាក់បញ្ញើចរន្ត (៛) | 278 | 535 | 744 | 60.0 | 92.6 | 38.9 |
| រូបិយវត្ថុផ្សេងៗ | 25,980 | 29,786 | 37,056 | 24.4 | 14.6 | 24.4 |
| ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ (៛) | 671 | 840 | 1,065 | -25.1 | 25.1 | 26.9 |
| ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស | 25,309 | 28,946 | 35,991 | 26.7 | 14.4 | 24.3 |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

នៅខែ មីនា ឆ្នាំ ២០១៥ រូបិយប័ណ្ណជាតិចរាចរនៅលើទីផ្សារមានចំនួនប្រមាណ ១៧,៦ ភាគរយ នៅក្នុងខណៈពេលដែលរូបិយប័ណ្ណបរទេសមានចំនួន ៨២,៤ ភាគរយ ។ កត្តានេះ បានបង្ហាញពីដុល្លារូបនីយកម្មនៅកម្ពុជានៅតែមានកំរិតខ្ពស់ ហើយនៅតែបន្តក្នុងកំរិតខ្ពស់តទៅមុខទៀត ។

ក្រាហ្វិកទី១÷ រូបិយបណ្ណចរាចរនៅលើទីផ្សារ




### ១.២.២. ឥណទាន

ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជនៅខែ មីនា មានកំណើន ៣,៦ ភាគរយ ឬ ២៥,៩ ភាគរយ ធៀបទៅនឹងខែដូចគ្នាឆ្នាំមុន ។ ក្នុងនោះ ការផ្តល់ឥណទានដល់គ្រឹះស្ថានហិរញ្ញវត្ថុមានកំណើន ៤,៦ ភាគរយ ឬ ៦៩,៥ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន ការផ្តល់ឥណទានដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមានកំណើន ៣,២ ភាគរយ ឬ ២២,៧ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន ការផ្តល់ឥណទានដល់តម្រូវការផ្ទាល់ខ្លួនមានកំណើន ៣,៩ ភាគរយ ឬ ៤៩,៣ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន និងការផ្តល់ឥណទានផ្សេងៗមានកំណើន ១៦,៣ ភាគរយ ឬ ១៧,២ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

ការផ្តល់ឥណទានដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមានចំនួន ៣៤,០៧៥ ពាន់លានរៀល ក្នុងនោះវិស័យសំណង់ ៨,៨ ភាគរយ សេវាកម្ម ៦៨,០ ភាគរយ កសិកម្ម ២១,១ ភាគរយ និងឧស្សាហកម្ម ១១,១ ភាគរយ ។

តារាង ១.២.២ ÷ ការផ្តល់ឥណទានដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ

| តាមវិស័យ | ២០១៥ | | | បម្រែបម្រួលធៀប | |
|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | ខែមុន | ឆ្នាំមុន |
| សំណង់ | 3,088 | 2,838 | 2,988 | 5.3 | 24.3 |
| សេវាកម្ម | 22,575 | 22,376 | 23,183 | 3.6 | 24.5 |
| កសិកម្ម | 4,017 | 4,024 | 4,130 | 2.6 | 28.3 |
| ឧស្សាហកម្ម | 3,731 | 3,770 | 3,774 | 0.1 | 7.4 |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

គិតត្រឹមខែ កុម្ភៈ ឆ្នាំ ២០១៥ ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៨,៨១៥ ពាន់លាន រៀល មានកំណើន ២,២ ភាគរយ ធៀបនឹងខែមុន ឬ ៥២,៦ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ឥណទានផ្តល់ដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគ្របដណ្តប់លើគណនីប្រមាណ ១,៧ លាននាក់ ដែល ៩០,០ ភាគរយ នៃឥណទានស្ថិតនៅតាមទីជនបទ ។ ទោះបីជាឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួនតិច ប៉ុន្តែកំណើនប្រចាំឆ្នាំនៅតែស្ថិតក្នុងកំរិតខ្ពស់ ។

រហូតមកដល់ខែ កុម្ភៈ ឆ្នាំ ២០១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណសរុបមានចំនួន ៤២ ក្នុងនោះមានគ្រឹះស្ថានហិរញ្ញវត្ថុធំៗចំនួន ៧ មានសិទ្ធិទទួលប្រាក់បញ្ញើ និងសន្សំ ដែលមានដូចជា ប្រាសាក់ អម្រឹត ស្ថាបនា ហត្ថាកសិករ អេអឹមខេ ក្រេឌីត និង វីសិនហ្វាន់ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗទាំង ៧ នេះ បានផ្តល់ឥណទានប្រមាណជា ៨៥ ភាគរយ នៃឥណទានសរុប រីឯគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣៥ ទៀត បានផ្តល់ឥណទានត្រឹមតែ ១៥ ភាគរយ នៃឥណទានសរុបប៉ុណ្ណោះ ។

អង្គការមិនមែនរដ្ឋាភិបាល NGOs ផ្តល់ឥណទានមានចំនួន ៣៦ ស្ថាប័នដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់ឥណទានប្រមាណ ១២០ ពាន់លានរៀល នៅខែ មករា ឆ្នាំ ២០១៥ ទៅដល់អ្នកខ្ចីចំនួន ៧ ម៉ឺននាក់ ។ បន្ទាប់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា ចេញសេចក្តីថ្លែងការណ៍រួមកាលពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ មាន NGOs ដែលផ្តល់ឥណទានចំនួន ៤០០ បានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ហើយធនាគារជាតិនៃកម្ពុជាកំពុងតែពិនិត្យមើល និងចេញអាជ្ញាប័ណ្ណជូនសម្រាប់តែ NGOs ណាដែលមានប្រតិបត្តិការមិនយកប្រាក់ចំណេញតែប៉ុណ្ណោះ ។

### ១.២.៣. អត្រាការប្រាក់

អត្រាការប្រាក់របស់ធនាគារពាណិជ្ជដែលទទួលបានពីធនាគារជាតិមានត្រឹមខែ ធ្នូ ឆ្នាំ ២០១៤ ។ អត្រាការប្រាក់មានការប្រែប្រួលកើនឡើងបន្តិចនៅចុងឆ្នាំ ២០១៤ ទាំងអត្រាប្រាក់បញ្ញើ និងប្រាក់កម្ចីជារៀល និងអត្រាប្រាក់បញ្ញើនិងប្រាក់កម្ចីជាដុល្លារ ប៉ុន្តែក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ អត្រាការប្រាក់របស់ធនាគារពាណិជ្ជមាននិន្នាការថយចុះ ។

តារាង ១.២.៣.ក ÷ អត្រាការប្រាក់របស់ធនាគារពាណិជ្ជ (%/ឆ្នាំ)

| អត្រាការប្រាក់ | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ |
| ប្រាក់បញ្ញើជារៀល | 6.58 | 6.16 | 4.91 | 5.80 | 6.02 |
| ប្រាក់កម្ចីជារៀល | 22.49 | 19.35 | 11.79 | 15.72 | 16.26 |
| ប្រាក់បញ្ញើជាដុល្លារ | 4.44 | 4.29 | 3.43 | 4.27 | 4.23 |
| ប្រាក់កម្ចីជាដុល្លារ | 17.15 | 15.36 | 11.61 | 11.35 | 11.51 |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការប្រែប្រួលតិចតួចនៅខែ កុម្ភៈ ឆ្នាំ ២០១៥ ហើយអត្រាការប្រាក់នេះបានថយចុះជាបន្តបន្ទាប់ ។

តារាង ១.២.៣.ខ÷ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (%/ឆ្នាំ)

| អត្រាការប្រាក់ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | ធ្នូ | មករា | កុម្ភៈ |
| គិតជាមធ្យមក្នុងមួយឆ្នាំ | 32.3 | 31.6 | 30.0 | 30.0 | 29.0 |
| គិតជាមធ្យមក្នុងមួយខែ | 2.7 | 2.6 | 2.5 | 2.5 | 2.4 |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

*សម្គាល់÷ អត្រាការប្រាក់ឥណទានគិតជាមធ្យមសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗ ចំនួន ៤ គឺហត្ថាកសិករ អម្រឹត ស្ថាបនា និង ប្រាសាក់។*

### ១.២.៤ អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារនៅខែ កុម្ភៈ ឆ្នាំ ២០១៥ មានចំនួន ៤.០២៧ រៀល ក្នុង១ដុល្លារ ដោយសង្កេតឃើញថាប្រាក់រៀលថ្លៃនៅដើមឆ្នាំនិងចុងឆ្នាំ ប៉ុន្តែបានចុះថ្លៃក្នុងកំឡុងខែកក្កដា-តុលា ។ ធនាគារជាតិបានអនុវត្តការលក់-ទិញប្រាក់ដុល្លារដើម្បីរក្សាស្ថិរភាពអត្រាប្រាក់រៀល ដែលក្នុងរយៈពេល៣ខែឆ្នាំ ២០១៥ ធនាគារជាតិបានប្រមូលប្រាក់ដុល្លារចូលចំនួន ២៤៥,៩៣ លានដុល្លារ ។ រីឯទុនបម្រុងជារូបិយប័ណ្ណបរទេសសុទ្ធកើនឡើងដល់ ៤.៤៥១ លានដុល្លារ នៅខែ មីនា ឆ្នាំ ២០១៥ ។

## ១.៣. វិស័យពាណិជ្ជកម្ម/Trades

**១.៣.១. ការនាំចូល÷** នៅក្នុងត្រីមាសទីមួយការនាំចូលសរុបជាទឹកប្រាក់ប្រមាណ ២.៧១២,៦ លានដុល្លារ ដែលកើនឡើង ២១,៣ ភាគរយ ធៀបទៅនឹងត្រីមាសទីមួយក្នុងឆ្នាំ ២០១៤ ។ នៅក្នុងនោះការនាំចូលផលិតផលវាយនភ័ណ្ឌកើនឡើង ១៣,៨ភាគរយ ការនាំចូល គ្រឿងយន្តបានកើនឡើង ២៣,១ភាគរយ ការនាំចូលប្រេងឥន្ធនៈកើនឡើង ១២,១ភាគរយ បរិក្ខាសំណង់សម្រេចបានកើនឡើង ០,២ភាគរយ និងការនាំចូលផលិតផលផ្សេងៗ កើនឡើង ២៩ភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ។

| តារាង ១.៣.១ ÷ តម្លៃនាំចូល ត្រីមាសទី១ ឆ្នាំ ២០១៥ (ឯកតាជាលានដុល្លារ) | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករនាំចូល | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៤ | ២០១៥ | បម្រែបម្រួលធៀប |
| | | | | | តម១ | តម១ | តម១/២០១៤ |
| **សរុបតម្លៃនាំចូល** | **6258.7** | **7420.6** | **8757.3** | **10296.0** | **2236.4** | **2712.6** | **21.3** |
| វាយនភណ្ឌ | 1839.5 | 2244.1 | 2661.7 | 2871.5 | 599.6 | 682.5 | 13.8 |
| បរិក្ខាសំណង់ | 180.9 | 246.7 | 284.8 | 386.2 | 98.8 | 99.1 | 0.2 |
| គ្រឿងយន្ត | 452.6 | 613.9 | 627.3 | 786.0 | 182.7 | 224.8 | 23.1 |
| ប្រេងឥន្ធនៈ | 831.1 | 942.3 | 997.0 | 1051.8 | 247.9 | 277.9 | 12.1 |
| ផ្សេងៗ | 2954.6 | 3373.7 | 4186.4 | 5200.5 | 1107.4 | 1428.4 | 29.0 |

*ប្រភព÷ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*
*សំគាល់÷ *ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

**១.៣.២. ការនាំចេញ÷** ក្នុងត្រីមាសទី១ ឆ្នាំ ២០១៥ នេះការនាំចេញសរុបរបស់កម្ពុជាសម្រេចបាន ២.១៧០ លានដុល្លារ ឬ បានកើនឡើង ៩,៨ ភាគរយ ធៀបទៅនឹងត្រីមាសទី១ ឆ្នាំ ២០១៤ ។ នៅក្នុងនោះការនាំចេញផលិតផលអង្ករបានកើនឡើង ៥៤,៥ ភាគរយ កៅស៊ូ ៣១,៥ ភាគរយ ផលិតផលកាត់ដេរកើនឡើង ៥,៨ ភាគរយ និងផលិតផលផ្សេងៗកើនឡើង ១៥,៩ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។

**វាយនភ័ណ្ឌ** នៅក្នុងត្រីមាស១ឆ្នាំ ២០១៥ នេះការនាំចេញផលិតផលវាយនភ័ណ្ឌសម្រេចបាន ១.៥៤៨,៨ លានដុល្លារ កើនឡើង ៥,៨ ភាគរយ ធៀបនឹងត្រីមាសទី១ឆ្នាំ ២០១៤ ។ ការនាំចេញប្រចាំខែក្នុងត្រីមាសទី១មាននិន្នាការថយចុះបន្តិចម្តងៗ បើតាមការសង្កេតទិន្នន័យនាំចេញផលិតផលវាយនភ័ណ្ឌរបស់កម្ពុជា ។

**អង្ករ** ការនាំចេញអង្ករនៅក្នុងត្រីមាសទី១ឆ្នាំ ២០១៥ សម្រេចបាន ៨៩.៥ លានដុល្លារ ឬ បានកើនឡើង ៥៤,៥ ភាគរយ ធៀបទៅនឹងត្រីមាសទី១ឆ្នាំ ២០១៤ ។ ការនាំចេញអង្ករនៅត្រីមាសទី១នេះមាននិន្នាការកើនឡើងជាមធ្យម ៥១.៦៣៨ តោន/ខែ ដែលចំនួននេះច្រើនជាងការនាំចេញជាមធ្យមក្នុងត្រីមាសទី១ ឆ្នាំ ២០១៤ ដែលនាំចេញ បានតែ ២៨.៦៧៥ តោន/ខែ ។

**កៅស៊ូ** ក្នុងត្រីមាសទី១នេះ ការនាំចេញកៅស៊ូសម្រេចបាន ៤១,៧ លានដុល្លារ ឬកើនឡើង ៣១,៥ ភាគរយ ធៀបទៅនឹងត្រីមាសទី១ឆ្នាំ ២០១៤ ។ ជាការកត់សម្គាល់ការនាំចេញកៅស៊ូក្នុងរយៈពេលបីខែដើមឆ្នាំ២០១៥ នេះមានទំហំធំជាង ការនាំចេញក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ដោយសារតម្លៃកៅស៊ូនៅទីផ្សារអន្តរជាតិបានងើបឡើងបន្តិចវិញបន្ទាប់ពីតម្លៃប្រេងក្នុងទីផ្សារអន្តរជាតិស្ទុះឡើងបន្តិចវិញនៅអំឡុងដើមខែមីនា ឆ្នាំ២០១៥ ។

| តារាង ១.៣.២ ÷ តម្លៃនាំចេញត្រីមាសទី១ ឆ្នាំ ២០១៥ (ឯកតាជាលានដុល្លារ) | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករនាំចេញ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៤ តម១ | ២០១៥ តម១ | បម្រែបម្រួលធៀប តម១/២០១៤ |
| **ការនាំចេញសរុប** | 4932.5 | 5573.8 | 6982.4 | 8106.0 | 1976.5 | 2170.1 | 9.8 |
| ផលិតផលកាត់ដេរ | 4259.6 | 4571.1 | 5386.6 | 5960.5 | 1464.0 | 1548.8 | 5.8 |
| អង្ករ | 106.6 | 136.0 | 262.3 | 248.5 | 57.9 | 89.5 | 54.5 |
| កៅស៊ូ | 200.6 | 164.4 | 175.2 | 154.9 | 31.7 | 41.7 | 31.5 |
| ផ្សេងៗ | 365.7 | 702.3 | 1158.3 | 1742.0 | 422.9 | 490.2 | 15.9 |

*ប្រភព÷ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*
*សំគាល់÷ *ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

## ១.៤ ស្ថានភាពការអនុវត្តថវិការដ្ឋ /Budget execution

### ១.៤.១ ការអនុវត្តចំណូល

នៅខែ មីនា ឆ្នាំ ២០១៥ នោរដ្ឋបាលកណ្តាលចំណូលក្នុងស្រុកអនុវត្តបានចំនួន ១.១៧៩,៦៨ ពាន់លានរៀល គឺខ្ពស់ជាង ៤៤,២៨ ភាគរយ ធៀបនឹងខែ មីនា ឆ្នាំមុន ។ ការកើនឡើងនេះ គឺដោយសារការកើនឡើងចំណូលរបស់ស្ថាប័នបីធំៗគឺ អគ្គនាយកដ្ឋានពន្ធដារចំនួន ៨៦,១៦ ភាគរយ អគ្គនាយក-ដ្ឋានគយ និងរដ្ឋករកម្ពុជាចំនួន ១៣,២៥ ភាគរយ និង អគ្គនា យកដ្ឋានទ្រព្យសម្បិត្តរដ្ឋ និងចំណូលមិនមែនសារពើពន្ធប្រមាណជា ៤៨,៨៤ ភាគរយ ។

ចំណូលចរន្តអនុវត្តបាន ១.១៧០,៥៤ ពាន់លានរៀល គឺខ្ពស់ជាង ៤៣,២៣ ភាគរយ បើធៀបនឹងខែ មីនា ឆ្នាំ ២០១៤ ក្នុងនោះ ចំណូលសារពើពន្ធបានកើនឡើង ៤៣,៣៨ ភាគរយ និងចំណូលមិនមែនសារពើពន្ធបានកើនឡើង ៤២,០៩ ភាគរយ ។ ចំណូលពន្ធផ្ទាល់អនុវត្តបាន ៣១៥,៤៩ ពាន់លានរៀល គឺបានកើនឡើង ៨១,៨៧ ភាគរយ បើធៀបនឹងខែ មីនា ឆ្នាំ ២០១៤ ក្នុងនោះការប្រមូលចំណូលពីពន្ធលើប្រាក់បៀវត្ស និងចំណូលពីពន្ធលើប្រាក់ចំណេញបានកើនឡើង ៥៥,១៨ ភាគរយ និង ៨៩,៣០ ភាគរយ រៀងគ្នា ។ ចំណូលពន្ធប្រយោលអនុវត្តបាន ៣៤៦,៥៨ ពាន់លានរៀល គឺទាបជាង ១០,៤៣ ភាគរយ បើធៀបនឹងខែ មីនា ឆ្នាំ ២០១៤ ។ ចំណែកឯ ចំណូលពន្ធពីពាណិជ្ជកម្មក្រៅប្រទេសអនុវត្តបាន ១៥៤,១៦ ពាន់លានរៀល គឺ ទាបជាង ៣,៦០ ភាគរយ បើធៀបនឹង ខែ មីនា ឆ្នាំ ២០១៤ គឺដោយសារការថមថយនៃពាណិជ្ជកម្មក្រៅប្រទេស ជាពិសេស ខាងផ្នែកនាំចេញ ។ ចំណូលមិនមែនសារពើពន្ធអនុវត្តបាន ១៣៧,៧១ ពាន់លានរៀល គឺខ្ពស់ជាង ៤២,០៩ ភាគរយ ដោយសារការកើនឡើងនៃចំណូលពីលិខិតឆ្លងដែននិងទិដ្ឋាការប្រមាណជា ១២៧,៥៥ ភាគរយ និង ចំណូលមិនមែនពន្ធផ្សេងទៀត (Other Non-tax Revenue) ប្រមាណជា ៨៩,៩២ ភាគរយ បើធៀបនឹងខែ មីនា ឆ្នាំ ២០១៤ ។

ជារួម នៅរយៈពេល៣ខែដើមឆ្នាំ ២០១៥ ចំណូលក្នុងស្រុកអនុវត្តបានចំនួន ២.៦៣៣,៥៤ ពាន់លានរៀល គឺទាបជាង ១,៣៨ ភាគរយ នៃគោលដៅរយៈពេលបីខែ[1] ប៉ុន្តែបានកើនឡើង ១៨,៦០ ភាគរយ បើធៀបទៅនឹងរយៈ ពេលដូចគ្នានៅឆ្នាំ ២០១៤ ក្នុងនោះចំណូលរបស់អគ្គនាយដ្ឋានពន្ធដារបានកើនឡើង ៤៥,៩៦ ភាគរយ អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានទ្រព្យសម្បិត្តរដ្ឋ និងចំណូលមិនមែនសារពើពន្ធ បានកើនឡើង ១,៩៤ ភាគរយ និង ១៧,១៩ ភាគរយ រៀងគ្នា ។ ចំណូលចរន្តអនុវត្តបាន ២.៦២៣,៧៤ ពាន់លានរៀល គឺ ទាបជាង ១,១៨ ភាគរយ នៃគោលដៅរយៈពេលបីខែ ប៉ុន្តែបានកើនឡើង ១៨,២៣ ភាគរយ គឺដោយសារការកើនឡើងនៃចំណូលសារពើពន្ធ ១៨,៣២ ភាគរយ និង ចំណូលមិនមែនសារពើពន្ធ ១៧,២១ ភាគរយ ធៀបរយៈពេលដូចគ្នាក្នុង ឆ្នាំ២០១៤ ។ ទន្ទឹមនឹងនេះ ចំណូលមូលធនអនុវត្តបាន ៩,៨០ ពាន់លានរៀល គឺ ខ្ពស់ជាង ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ។

### ១.៤.២ ការអនុវត្តចំណាយ

នៅខែ មីនា ឆ្នាំ ២០១៥ ចំណាយសរុបនៅរដ្ឋបាលកណ្តាលអនុវត្តបាន ៨១០,៩៤ ពាន់លានរៀល គឺទាបជាង ២៤,៧៥ ភាគរយ បើធៀបនឹងខែ មីនា ឆ្នាំ ២០១៤ ដោយសារការថយចុះទាំងចំណាយចរន្ត និងចំណាយមូលធន ។

នៅខែ មីនា ឆ្នាំ ២០១៥ ចំណាយចរន្តអនុវត្តបាន ៥៦០,៤៦ ពាន់លានរៀល គឺទាបជាង ២,៣២ ភាគរយ បើធៀបនឹងខែ មីនា ឆ្នាំ ២០១៤ ក្នុងនោះ ចំណាយចរន្តសម្រាប់ក្រសួងអាទិភាពអនុវត្តបានទាបជាង ២៥,០៥ ភាគរយ ។ ជារួម ការអនុវត្តថវិកានៅរយៈពេល៣ខែដើមឆ្នាំ ២០១៥ ចំណាយរបស់ក្រសួងអាទិភាពអនុវត្តបាន ២៦៥.៧០០ លានរៀល គឺទាបជាង ២២,៤២ ភាគរយ បើធៀបទៅនឹងការអនុវត្តរយៈពេលដូចគ្នាឆ្នាំ ២០១៤ ក្នុងនោះ ក្រសួងមួយចំនួនបានបន្ថយល្បឿននៃការចំណាយដូចជា÷ ការថយចុះនៃចំណាយក្រសួងអប់រំយុវជន និងកីឡា ២៥,៦៩ ភាគរយ ចំណាយក្រសួងយុត្តិធម៌ ១៤,៧២ ភាគរយ ចំណាយក្រសួងអភិវឌ្ឍន៍ជនបទ ៣៥,៧២ ភាគរយ និង ចំណាយរបស់ក្រសួងកិច្ចការនារី ១៩,១១ ភាគរយ និង ចំណាយក្រសួងសុខាភិបាល ២១,៩៣ ភាគរយ ប៉ុន្តែ ក្រសួងផ្សេងទៀតមានការកើនឡើងរួមមាន÷ ការកើនឡើងនៃចំណាយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ៧,៧២ ភាគរយ និង ចំណាយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៦,៣១ ភាគរយ និង ចំណាយក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ ១៣,៣៨ ភាគរយ ។

ជារួមនៅដើមឆ្នាំ ២០១៥ នេះ ចំណាយសរុបអនុវត្តបានចំនួន ១.៩៥៨,០៨ ពាន់លានរៀល គឺទាបជាង ១១,២២ ភាគរយ នៃគោលដៅរយៈពេល៣ខែ ឬ បានថយចុះ ២៥,២៣ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ដោយសារការពង្រឹងការអនុវត្តថវិកាតាមកម្មវិធី អង្គភាពថវិកាត្រូវបានដាក់ឲ្យអនុវត្តដំបូង ដែលធ្វើឲ្យមានភាពរអាក់រអួលខ្លះៗក្នុងការអនុវត្តថវិការបស់អង្គភាពទាំងនោះ ។

នៅខែ មីនា ឆ្នាំ ២០១៥ តុល្យភាពថវិកាចរន្តអតិរេកសាច់ប្រាក់ចំនួន ៦៨៣,៦៣ ពាន់លានរៀល ។ ជារួម នៅរយៈពេល៣ខែដើមឆ្នាំ ២០១៥ តុល្យភាពថវិកាចរន្តអតិរេកសាច់ប្រាក់ចំនួន ៨៩៤,០៤ ពាន់លានរៀល ។

[1] គោលដៅប្រមូលរយៈពេលបីខែ = (ច្បាប់ថវិកាប្រចាំឆ្នាំ/១២)* ៣ខែ

## ១.៥ ស្ថានភាពវិនិយោគឯកជន/Private investment

គម្រោងវិនិយោគឯកជនដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានកើនឡើងនៅដើមឆ្នាំ ២០១៥ ប៉ុន្តែទាបជាងឆ្នាំកន្លងទៅ ។ នៅខែ មីនា ឆ្នាំ ២០១៥ មានចំនួន ២២ គម្រោង គឺកើនឡើង ៦៩,២ ភាគរយ រីឯទុនវិនិយោគមានប្រមាណជា ២.៧៩៥ លានដុល្លារ គឺបានកើនឡើងខ្ពស់ ការបង្កើតការងារបាន កើនឡើង ៧៨,៤ ភាគរយ ធៀបនឹងខែ មីនា ឆ្នាំ ២០១៤ ។

ក្នុងរយៈពេល៣ខែដើមឆ្នាំនេះ ចំនួនគម្រោងបានថយចុះ ១៤,២ ភាគរយ ប៉ុន្តែចំនួនទុនវិនិយោគមានការកើនឡើងជាពិសេសនៅខែ មីនា និង ការបង្កើតការងារក៏មានកំណើនប៉ុន្តែ ក្នុងកម្រិតទាបជាងការរំពឹងទុក (សូមមើលតារាង ១.៥) ។

តារាង ១.៥÷ ស្ថានភាពវិនិយោគឯកជន និង កំណើនជាភាគរយ

| សូចនាករវិនិយោគ | ឯកតា | ២០១៥ | | | | កំណើន (%)* | |
|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | ៣ខែ | មីនា | ៣ខែ |
| ចំនួនគម្រោង | គម្រោង | 10 | 5 | 22 | 37 | 69.2 | -14.2 |
| ចំនួនទុនវិនិយោគ | លាន $ | 62.4 | 16.0 | 2,795 | 2,873 | 1,249.0 | 573.0 |
| ការបង្កើតការងារ | ពាន់នាក់ | 9,711 | 8,343 | 27,508 | 45,562 | 78.4 | 0.2 |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
*សំគាល់៖ * ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

## ១.៦ ស្ថានភាពទេសចរណ៍/Tourism

ភ្ញៀវទេសចរណ៍អន្តរជាតិសរុបមកទស្សនកិច្ចកម្ពុជានៅត្រីមាសទី១ឆ្នាំ ២០១៥ មានចំនួន ១.៣០៧,៨ ពាន់នាក់ ឬ បានកើនឡើង ៣.១ ភាគរយ ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ ២០១៤ (សូមមើលតារាង ១.៦)។ ក្នុងនោះ ភ្ញៀវទេសចរអន្តរជាតិតាមច្រកអាកាសអន្តរជាតិភ្នំពេញបានកើនឡើងប្រហែល ១១ ភាគរយ ។ កំណើនប្រកបដោយចីរភាពនេះ នៅតែបន្តមានសម្រាប់រយៈពេលខ្លី និងមធ្យម ដោយសារ វិស័យទេសចរណ៍នៅកម្ពុជានៅតែបន្តជម្រុញការអភិវឌ្ឍន៍ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ តំបន់អាស៊ាននៅតែជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិ និង ទី៣គឺ ភាពធូរស្បើយនៃវិបត្តិសេដ្ឋកិច្ចសកលលោក ក៏ដូចជាស្ថិរភាពនយោបាយក្នុងតំបន់ ។

| តារាង ១.៦÷ ចំនួនភ្ញៀវទេសចរអន្តរជាតិ (ឯកតាគិតជា ពាន់នាក់) និង កំណើន (%) | | | | | | |
|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | ២០១៥ | | | | កំណើនជាភាគរយ (ភាគរយ)* | |
| | មករា | កុម្ភៈ | មីនា | ៣ខែ | មីនា | ៣ខែ |
| **ភ្ញៀវទេសចរអន្តរជាតិសរុប** | **460.5** | **430.2** | **417** | **1,307.8** | **4.2** | **3.1** |
| តាមអាកាស | 262.3 | 241.7 | 229.3 | 733.4 | 12.2 | 4.9 |
| ច្រកអន្តរជាតិភ្នំពេញ | 93.8 | 84.3 | 94.4 | 178.1 | 21.9 | 11.2 |
| ច្រកសៀមរាប | 168.5 | 157.4 | 134.9 | 326 | 6.3 | 1.5 |
| តាមផ្លូវគោកនិងទឹក | 198.2 | 188.5 | 187.6 | 386.7 | -4 | 1 |

*ប្រភព៖ ក្រសួងទេសចរណ៍*
*សំគាល់៖ * ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

## ១.៧ ស្ថានភាពសំណង់/Construction

ស្ថានភាពសំណង់ក្នុងខែ មីនា ឆ្នាំ ២០១៥ នេះ មានការវិវត្តគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងខែមុន និងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ ។ ប៉ុន្តែក្នុងរយៈពេល៣ខែដើមឆ្នាំ ២០១៥ នេះ ស្ថានភាពសំណង់ទូទាំងប្រទេសមានការថយចុះ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៤ ។ គម្រោងសំណង់បានថយចុះ ២៣ ភាគរយ គឺពី ៤៧៨ មក ៣៦៨ ផ្ទៃក្រឡាសាងសង់ បានធ្លាក់ចុះ ពី ២.៦០៣,៥ មក ១.៤១២,៣ ពាន់ម៉ែត្រការ៉េ និងការវិនិយោគជាទឹកប្រាក់ក៏បានធ្លាក់ចុះ ៥២,៧ ភាគរយ ផងដែរ (សូមមើលតារាង១.៧) ។ ស្ថានភាពសាងសង់បានថយចុះនៅដើមឆ្នាំនេះ អាចជាសញ្ញាថយល្បឿននៃវិស័យសំណង់ តាមការសង្កេត ។

| តារាង ១.៧÷ ស្ថានភាពសំណង់ និង កំណើន (%) | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករសំណង់ | ឯកតា | ២០១៥ | | | | កំណើន (%)* | |
| | | មករា | កុម្ភៈ | មីនា | ៣ខែ | មីនា | ៣ខែ |
| សរុបចំនួនគម្រោង | គម្រោង | 110 | 115 | 143 | 368 | 7 | -23 |
| សរុបជាផ្ទៃក្រឡា | ពាន់ម$^{2}$ | 139.2 | 191.6 | 1,081.5 | 1,412.3 | 100 | -45.8 |
| សរុបជាទឹកប្រាក់ | លានដុល្លារ | 43.4 | 52.8 | 349.2 | 445.3 | 84 | -52.7 |

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*
*សំគាល់៖ * ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៤*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗលើពិភពលោក/International commodities price

**ប្រេងឆៅ**÷ នៅខែ មីនា ឆ្នាំ ២០១៥ តម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (WTI) សម្រាប់កិច្ចសន្យាលក់មួយខែខាងមុខបានថយចុះ ៥,៦ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៥០,៦ ដុល្លារ/ធុង មក ៤៧,៧ ដុល្លារ/ធុង ។ ចំពោះប្រេងឆៅ (Brent) បានថយចុះ ៣,៧ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៥៧,៩ ដុល្លារ/ធុង មក ៥៥,៧ ដុល្លារ/ធុង ។

**អង្ករថៃ**÷ នៅខែ មីនា ឆ្នាំ ២០១៥ នៅទីក្រុងបាងកកអង្ករនាំចេញ (ខ្ទេច ២៥ ភាគរយ) បានថយចុះតម្លៃបន្តិចមកនៅត្រឹម ៣៦០.៧៤ ដុល្លារ/តោន ធៀបទៅនឹងខែមុនដែលមានតម្លៃ ៤០០ ដុល្លារ/តោន ។ ប៉ុន្តែ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន តម្លៃអង្ករមានការកើនឡើងបន្តិចប្រមាណជា ១ ភាគរយ ។ ទន្ទឹមនឹងថ្លៃអង្ករលើទីផ្សារធ្លាក់ចុះនេះ ការដាក់ឱ្យដេញថ្លៃស្តុកអង្ករជាលើកទី៣ ត្រូវបានរដ្ឋាភិបាលថៃពន្យាពេលក្នុងគោលបំណងបង្ការការបន្តធ្លាក់ថ្លៃ ។ ម្យ៉ាងវិញទៀត គណៈកម្មាធិការគោលនយោបាយស្រូវអង្កររបស់ថៃ (The Rice Policy Committee in Thailand) បានឧបត្ថម្ភធនថវិកាប្រមាណជា ១៨ លានដុល្លារ ដល់រោងម៉ាស៊ីនកិនស្រូវដែលជាការជម្រុញការប្រមូលស្តុកស្រូវនារដូវប្រមូលផល ។

**អង្ករវៀតណាម**÷ នៅខែ មីនា ឆ្នាំ២០១៥ អង្ករនាំចេញ (ខ្ទេច ៥ ភាគរយ) មានតម្លៃ ៣៩២ដុល្លារ/តោន បានកើនឡើង ៧,១ ភាគរយ ធៀបទៅនឹងខែមុន ប៉ុន្តែ បានធ្លាក់ចុះប្រមាណជា ៥ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ បើធៀបទៅនឹងអង្ករនាំចេញរបស់ថៃ (ខ្ទេច ៥ ភាគរយ) ដែលមានតម្លៃ ៤១១ ដុល្លារ/តោន អង្ករវៀតណាមនៅមានតម្លៃថោកជាងអង្កររបស់ថៃដដែល បើទោះបីជាអង្ករថៃបានថយចុះតម្លៃបន្តិចក៏ដោយកត្តី ។ បើតាមសមាគមស្បៀងរបស់វៀតណាម (Vietnam Food Association) បានឱ្យដឹងថា ក្នុងឆ្នាំ ២០១៥ នេះ ក្រុមហ៊ុននាំអង្ករចេញវៀតណាម បានចុះហត្ថលេខាលើកិច្ចសន្យានាំអង្ករចេញប្រមាណជាជិត ២ លានតោន គឺកើនលើសពីឆ្នាំកន្លងទៅប្រមាណជា ៧ ភាគរយ ដែកប្រការនេះ ទំនងជានឹងជួបបញ្ហាការផ្គត់ផ្គង់ទីផ្សារលើសពីតម្រូវការ ដែលនាំទៅរកការធ្លាក់ថ្លៃអង្ករជាបន្តទៀត ។

**ថ្លៃកៅស៊ូ** ÷ នៅខែ មីនា ឆ្នាំ ២០១៥ កៅស៊ូឆៅស្តង់ដារ TSR 20 មានថ្លៃ ១,៤៣ ដុល្លារ/គីឡូ គឺបានកើនឡើង ១,០ ភាគរយ បើប្រៀបធៀបទៅនឹងខែមុន ដែលថ្លៃ ១,៤១ ដុល្លារ/គីឡូ (សូមមើលតារាង ២.) ។

| តារាង÷ ២. ស្ថានភាពថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | ឯកតា | ២០១៤ | | ២០១៥ | | | បម្រែបម្រួល (%) |
| | | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មីនា/ មីនា ២០១៤ |
| ប្រេងឆៅ (Average) | $/bbl | 76.9 | 60.7 | 47.1 | 54.7 | 52.8 | -49.2% |
| Brent | $/bbl | 78.4 | 62.3 | 48.1 | 57.9 | 55.7 | -48.1% |
| Dubai | $/bbl | 76.7 | 60.52 | 45.9 | 55.8 | 54.9 | -47.3% |
| WTI | $/bbl | 75.8 | 59.2 | 47.2 | 50.6 | 47.7 | -52.5% |
| អង្ករថៃ A.1 (១០០%) | $/mt | 423 | 421 | 418 | 417 | 410 | -2.8% |
| ថ្លៃអង្ករ (៥% វៀតណាម) | $/mt | 422 | 382 | 374 | 353 | 392 | 7.1% |
| ថ្លៃអង្ករ (៥% ថៃ) | $/mt | 418 | 418 | 420 | 420 | 411 | -3.3% |
| ថ្លៃអង្ករ (២៥% ថៃ) | $/mt | 400 | 398 | 400 | 400 | 360 | -4.7% |
| កៅស៊ូ (TSR20) | $/Kg | 1.54 | 1.48 | 1.42 | 1.41 | 1.43 | -25.6% |
| កៅស៊ូ (SGP/MYS) | $/Kg | 1.64 | 1.60 | 1.65 | 1.81 | 1.74 | -23.9% |
| *ប្រភព÷ ធនាគារពិភពលោក* | | | | | | | |

********

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Construction Approval in P-Penh (m2)**




Source: Min. LMUC

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

**Tourist Arrivals ('000 persons)**




Source: Ministry of Tourism

# អតិផរណា និង ទុនបំរុងបរទេស (Inflation and Foreign Reserves)




Source: NBC




Source: NIS




Source: NIS




Source: NIS




Source: NIS




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate R/100Đ and R/B**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)


















# ការអនុវត្តថវិកា (Budget)


















# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

CDC Approval, Fixed Assets and Growth (Mn. $)




Source: CDC

CDC Approvals- Fixed Assets by Sectors (Mn. $)




Source: CDC

Number of Jobs ('000 person)




Source: CDC

Public Investment by Source of Finance (Bn.R)




Source: MEF

Net Loans Disbursement (Bn.R)




Source: MEF

CDC Approvals, Fixed assets by Sources (Mn. $)




Source: CDC

# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

## <u>កំណត់សម្គាល់</u>

កៅស៊ូ÷

- កៅស៊ូ TSR 20 : Technically Specific Rubber ឬហៅបានម្យ៉ាងទៀតថា ISNR 20 : Indian Standards Naturally Rubber ជាប្រភេកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ផលិតជាកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើង អាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយស្រួលលាយបញ្ចូលជាមួយសារធាតុដទៃទៀត ដែលធ្វើឱ្យផលិតផលដែលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់ និងមិនងាយសឹងរិចរិល។
- Rubber (Asia), RSS3 Grade, Singapore Commodity Exchange Ltd (SICOM) Nearby Contract Beginning 2004; During 2000 To 2003, Singapore RSS1; Previously Malaysia RSS1 [RUBBER1_MYSG] **UNITS:** ($/kg) | **SOURCE:** Singapore Exchange Ltd (SGX Previously SICOM); Bloomberg; Rubber Association Of Singapore Commodity Exchange (RASCE); International Rubber Study Group; Asian Wall Street Journal; World Bank.
- RSS 3 : Ribbed Smoked Sheets ជាប្រភេទកៅស៊ូដែលចំរាញ់ចេញពីដើមដែលមានគុណភាពខ្ពស់។ កៅស៊ូប្រភេទនេះត្រូវបានកែច្នៃហើយមានទ្រង់ទ្រាយជា សន្លឹក និងជាដុំស្ងួត។ RSS 3 ប្រើប្រាស់សម្រាប់ផលិតជា កង់រថយន្ត និងបំពង់ទីបជ័រ និងស្បែកជើង។ ជាទូទៅវាត្រូវបានគេប្រើប្រាស់ច្រើននៅក្នុងឧស្សាហ៍កម្មផលិតសំបកកង់រថយន្ត ហើយជាង ៥០ភាគរយ នៃផ្នែកសំខាន់របស់ផលិតផលត្រូវបានផលិតពីកៅស៊ូនេះ។

ប្រេងឆៅ÷

ប្រេងឆៅដែលបានបង្ហាញក្នុងតារាង ២.០ ជាប្រភេទប្រេងឆៅធនស្រាន (Light Crude Oil) ដែលគេធ្វើការទិញលក់ជាលក្ខណៈកិច្ចសន្យាអនាគត (Future Contract) ។ ប្រេងឆៅនៅក្នុងទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ WTI (West Texas Intermediate) ប្រភេទប្រេងរបស់អាមេរិក, Brent ប្រភេទប្រេងរបស់ អង់គ្លេស និង Dubai ជាប្រភេទប្រេងរបស់ប្រទេសអារ៉ាប់បីសាអ៊ូឌីត។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាម កម្រិតភាព ស្រាលហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេ អាចចំរាញ់ ចេញជាប្រេងឥន្ធៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់ក្នុងការវាស់វែងភាពស្រាលនៃប្រភេទ ប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែល មានកម្រិត API Gravity កាន់តែខ្ពស់ គឺជាប្រភេទប្រេងដែល កាន់តែស្រាល និងអាចចំរាញ់ចេញជាប្រេងឥន្ធនៈបានច្រើន។

- WTI $40^{o}$ API
- Brent $38^{o}$ API
- Dubai $32^{o}$ API

# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ប្រចាំខែ មីនា ឆ្នាំ ២០១៥**/March, 2015


*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិ*

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ*

*ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*Statistics Department*

*General Department of Economic and Public Finance Policy*

*Ministry of Economy and Finance*



*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*១ លោក ឆូវ សុមេធា*

*២ លោក សុខ ឧន*

*៣ លោក ហាក់ សុផល*

*ម៉ោងធ្វើការ៖ ៧:០០ ដល់ ១១:០០ ព្រឹក*

*២:០០ ដល់ ៥:០០ រសៀល*

*ទូរស័ព្ទលេខ៖ ០២៣ ៤២៧ ៩១៣*